**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើត ការគ្រប់គ្រង និងការចាត់ចែងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ និងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការបង្កើត ការគ្រប់គ្រង និងការចាត់ចែងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិនិងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ដែលសរសេរជាអក្សរកាត់ថា **ម.ស.ជ.**។

**មាត្រា២ ._**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិឲ្យមានប្រសិទ្ធភាព ដើម្បីជួយទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ ._**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ នៅក្នុងព្រះរាជា-ណាចក្រកម្ពុជា ។

## ជំពូកទី២

## ប្រភពធនធាននិងការគ្រប់គ្រងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

**មាត្រា៤ ._**

មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានប្រភពធនធានមកពី៖

- វិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល
- វិភាគទានរបស់ស្ថាប័នជាតិផ្សេងៗទៀត
- ចំណែកនៃប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈពីវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- ជំនួយរបស់អង្គការជាតិនិងអន្តរជាតិនានា
- អំណោយពីសប្បុរសជន វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- ប្រភពធនធានផ្សេងៗទៀត។

រាល់ធនធានខាងលើ ត្រូវបញ្ចូលក្នុងគណនីមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ។

**មាត្រា៥ ._**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវបង្កើតគណនីមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិដោយឡែកសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- អភិរក្សនិងអភិវឌ្ឍសិល្បៈជាតិ ពិសេសទម្រង់សិល្បៈដែលកំពុងប្រឈមនិងត្រូវសង្គ្រោះបន្ទាន់
- សិក្សាស្រាវជ្រាវនិងបង្កើតស្នាដៃ
- ផ្សព្វផ្សាយនិងលើកតម្លៃសិល្បៈជាតិ
- បណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យសិល្បៈ
- ការងារផ្សេងៗទៀតដែលពាក់ព័ន្ធ។

**មាត្រា៦ ._**

នីតិវិធីនៃការប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

**មាត្រា៧ .-**

មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

សមាសភាពគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ រួមមាន៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - តំណាងក្រសួងព័ត៌មាន | ១រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ | | លេខាធិការអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៨ .-**

គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កំណត់គោលនយោបាយ យុទ្ធសាស្ត្រគ្រប់គ្រងនិងចាត់ចែងប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន បណ្តាដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជនក្នុងការកៀរគរធនធានសម្រាប់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- ពិនិត្យនិងសម្រេចលើគម្រោងចំណូលចំណាយរបស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ សម្រាប់បម្រើឲ្យការទ្រទ្រង់និងការអភិវឌ្ឍសិល្បៈជាតិ តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន
- តាមដានការអនុវត្តនិងពិនិត្យលើរបាយការណ៍អំពីស្ថានភាពការងារ និងដំណើរការរបស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីដំណើរការមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ និង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូននិងតាមការចាំបាច់ ដែលបម្រើឲ្យមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

**មាត្រា៩ .-**

គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅទីស្តីការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងដឹកនាំដោយលេខាធិការអចិន្ត្រៃយ៍។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

**មាត្រា១០ .-**

គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានត្រាដោយឡែកសម្រាប់ដំណើរការការងារ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ